# សិលាចារឹកទួលព្រះវិហារ K.1397

សិលាចារឹកនេះ រកឃើញដោយលោកតា អ៊ួន ឡាក់ ជាប្រជាពលរដ្ឋរស់នៅទួលព្រះវិហារ ស្ថិតនៅក្នុងភូមិត្រពាំងត្រាវ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ។ កាលពីអំឡុងដើមទសវត្សឆ្នាំ១៩៧០ លោកតាបានជីកលេណដ្ឋាន នៅក្បែរផ្ទះរបស់គាត់ ក៏បានប្រទះឃើញសិលាចារឹកនេះ និងបានកប់ទៅវិញ។ លុះក្រោយឆ្នាំ១៩៧៩ គាត់បានគាស់យកសិលាចារឹកនេះ និងផ្លាស់ប្ដូរទីតាំងរក្សាទុកជាច្រើនដង បន្ទាប់មកក៏បានយកទៅកប់ដីម្ដងទៀត ព្រោះមានក្ដីបារម្ភអំពីសុវត្ថិភាពសិលាចារឹកនេះ។ ដោយមានការសម្របសម្រួលពីលោក ម៉ៅ ឌឹម នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៨ លោកតាបានគាស់យកសិលាចារឹកនេះដើម្បីឱ្យលោកសាស្ត្រាចារ្យ យាង វីរបុត្រ ផ្ដិតសំណៅនិងសិក្សា ដើម្បីបានដឹងអំពីអត្ថន័យសិលាចារឹកនេះ។ ក្រោយមក ក្នុងអំឡុងឆ្នាំ២០០៩-២០១០ សិលាចារឹកនេះបានយកទៅរក្សាទុកនៅសារមន្ទីរខេត្តតាកែវ បន្ទាប់មកនៅក្នុងខែកក្កដា ឆ្នាំ២០១៧ សិលាចារឹកនេះបានយកមកជួសជុលនៅសារមន្ទីរជាតិភ្នំពេញ។

សិលាចារឹកនេះ ចារនៅលើថ្មថ្ងើមអណ្ដើក ព៌ណ៌ក្រមៅ គ្រាប់ថ្មម៉ដ្ឋ មានកម្ពស់ ៩៣ ស.ម. បន្ទារ ៣៤ ស.ម. និងកម្រាស់ ៨ ស.ម.។ តាមរូបរាងសណ្ឋានសិលាចារឹកនេះ ថ្មដែលជ្រើសរើសមកចារ ជាថ្មដែលធ្លាប់ប្រើប្រាស់កន្លងមក នៅពេលយកមកចារក៏មិនបានសម្អិតសម្អាង និងលៃរូបរាងឱ្យបានសមរម្យឡើយ។ ចំណែកអក្សរចារឹកនៅលើនោះចារស្រាលៗ នាំឱ្យកន្លែងខ្លះមើលមិនសូវច្បាស់[១] កន្លែងខ្លះទៀតចារខុះពាក្យពេជន៍ ដែលបង្ហាញឱ្យឃើញពីលក្ខណៈប្រញាប់ប្រញាល់ ដើម្បីចារសិលាចារឹកនេះឡើង។

អត្ថបទចារឹកមានចំនួន២០បន្ទាត់ ចុះកាលបរិច្ឆេទនៅឆ្នាំ៨២៩ មហាសករាជ ត្រូវនឹងឆ្នាំ៩០៧ នៃគ្រិស្តសករាជ។ ទោះបីជាសិលាចារឹកនេះមានការដាច់រលុបត្រង់ចំណុចខ្លះ របេះបាក់ផ្ទៃថ្មខ្លះ ប៉ុន្តែយើងនៅតែអាចអានយល់សេចក្ដីនៃសិលាចារឹកនេះ ដែលមានខ្លឹមសារស្ដីពីព្រះរាជបញ្ជារបស់ព្រះមហាក្សត្រត្រាស់ដល់ក្រុមមន្ត្រី ឱ្យចាត់ចែងចារ

[១] កន្លែងខ្លះសឹករេចរឹលដោយកត្តាមនុស្ស។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

សិលាចារឹក កំណត់ព្រំប្រទល់ដីស្រែ និងឱ្យដីស្រែនោះដល់ក្រុមគ្រួសារវាបភូរិវល្ល វាបបុរុសសីវ វាបនិរន្តរទេហ វាបកុសិនា ដែលបានស្នើសុំកន្លងមក។ នៅក្នុងសិលាចារឹកនេះក៏មានបង្ហាញស្ថាននាម «សិវបុរ»[២] ដែលជាឈ្មោះបុរាណរបស់ប្រាសាទភ្នំបាយ៉ង់ នៅស្រុកគិរីវង់ ខេត្តតាកែវ។ យើងពុំទាន់យល់ច្បាស់ថាមានទំនាក់ទំនងអ្វី រវាងទីតាំងរកឃើញសិលាចារឹកនេះ ជាមួយទីតាំងប្រាសាទភ្នំបាយ៉ង់នៅឡើយទេ ដ្បិតទីតាំងនេះមានចម្ងាយត្រង់ឆ្ងាយពីគ្នាប្រហែល៧៥ គីឡូម៉ែត្រ។ ឬក៏មានទីតាំងមួយនៅម្តុំនោះឃុំពត់សរ ស្រុកបាទីនោះ មានឈ្មោះពីបុរាណថា «សិវបុរ» ដូចគ្នានឹងប្រាសាទភ្នំបាយ៉ង់ដែរ?

**អត្ថបទដើមជាអក្សរខ្មែរទំនើប**

១. ៨២៩គកនុមា(ន)[៣]វ្រះគាសន

២. ធូលីវ្រះបាទធូលីជេងវ្រះ

៣. កំម្រតេង៑[[អញ៑]][1]តម្រតាញ៑គ្រីស

៤. មរសិង្គនុម្រតាញ៑-◌្រ-(វា)

៥. បិសកប្រេប្រត្យយ(បិ[[ប្រេ?]])-

៦. (វា)បិបិ(ត)-(ថា)រិប្រេគ(ស្ត)--

៧. --រន[[បាល?]]ប្រេមោក៑ឱយ

៨. ប្រាសាទស្រេប្រេត-----

៩. ◌្រ-----តិស្វំបិឱយ

១០. តកុលេវាបិភូរិវល្ហូវា(បិ)

១១. បុរុបគីរវាបិនិរន្តរទេហ

១២. វាបិកុគិនា(រ?)ឱយ--(ប្រគស្ត)

១៣. អំវិតគិប្រគស្តទៅ(វាយ?)

១៤. វ្យនាគោលិអំវិ(តគិប្រគស្ត)

---

[២] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/3663

[៣] អ្នកចារជួសអក្សរនេះស្រាលៗនៅខាងលើ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

១៥. ទៅទក្សិនល្វះនា----តស្រេ

១៦. បរមវិន្ទុត----(ប្រសបិ?)

១៧. ទៅបត្ចិមទៅ[[ឧត្តរ?]]នាគោល

១៨. (អំវិតតិ)ប្រគស្ត(ភូមិ?)ត

១៩. គោលិទៅវា(យវ្យ)--

២០. --(ត)ព្រះកំម្រតេងអញ្ជិតិវបុរ

## អត្ថបទប្រែសម្រួល

(នា)ឆ្នាំ៨២៩នៃមហាសករាជ មានព្រះរាជសាសន៍(/ព្រះរាជបញ្ជា)ធូលីព្រះបាទធូលីជើងព្រះគម្តែងអញ ដល់ម្រតាញស្រីសមរសិទ្ធ និងម្រតាញ--- និងវាបសក ប្រើរាជបម្រើ(ឱ្យប្រើ)វាបបិតចារសិលាចារឹក។ (ទ្រង់ត្រាស់)ប្រើមកឱ្យព្រះរាជទានដីស្រែ ប្រើឱ្យដល់---ដែលបានសុំ(កន្ទងមក) ឱ្យដល់គ្រួសារវាបភូវិល្វ វាបបុរុសសីវ វាបនិវន្តរទេហ វាបកុសិនារ។ (ដីស្រែនោះមានព្រំប្រទល់) អំពីសិលាចារឹកនេះទៅដល់ខាងពាយ័ព្យត្រង់(ថ្ម)គោល, អំពីសិលាចារឹកនេះទៅខាងត្បូងលុះដល់--- ដល់ស្រែបរមវិន្ទុ---- ប្រសព្វទៅខាងលិចទៅខាងជើងត្រង់(ថ្ម)គោល, អំពីសិលាចារឹកដីភូមិនេះដល់គោលទៅខាងពាយ័ព្យ---ស្រុកព្រះគម្តែងអញសិវបុរៈ។

## វាក្យសព្ទសំខាន់ៗ

**ធូលីវ្រះបាទធូលីជេងវ្រះកំម្រតេងអញ** ឋានន្តរនាមសម្គាល់ព្រះមហាក្សត្រ។

**ប្រត្យយ** រាជបម្រើ អ្នកបម្រើស្តេច មន្ត្រីបម្រើស្តេច។

**ប្រគស្ត** សិលាចារឹក។

**ប្រសាទ** ប្រទាន ឱ្យ។

**ម្រតាញ** ឋានន្តរនាមមន្ត្រីបំពេញមុខងារនៅរាជវាំង ប្រាសាទ មានមុខងារជាអភិបាល ជាតម្រួតជាដើម។

**វាប** ឋានន្តរនាមមន្ត្រីថ្នាក់ទាប។

**វ្រះគាសន** ព្រះរាជសាសន៍ ព្រះរាជបញ្ជា។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព





រូបថតនិងសំណៅផ្តិតសិលាចារឹក K. 1397 (រូបថត៖ ហ៊ុន ឈុនតេង)




ផែនទីបង្ហាញទីតាំងទួលព្រះវិហារ កន្លែងរកឃើញសិលាចារឹក K. 1397 (រូបថត៖ Google Earth)

# ឯកសារយោង

ហ៊ុន ឈុនតេង,

(២០២១). *របៀបចាត់ចែងពេលហ្លួងសុវណ្ណគត*. ASM Khmer Civilization.
https://ams.com.kh/khmercivilization/detail/3663

អត្ថបទដោយ៖ ហ៊ុន ឈុនតេង